**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ១៣០/២០ **ក.ប**/ស.ណ.ន.ក.ក.ស

# សេចក្តីណែនាំ
# ស្តីពី
# ការអនុញ្ញាតឱ្យបើកដំណើរការឡើងវិញគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រោមឱវាទក្រសួង ចាប់ពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០

យោងតាមសេចក្តីប្រកាសព័ត៌មានស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ សាលាបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវបានអនុញ្ញាតឱ្យបើកដំណើរការឡើងវិញ ដោយត្រូវគោរពឱ្យបានខ្ជាប់ខ្ជួននូវវិធានការសុខាភិបាល។

ដើម្បីធានាបានសុវត្ថិភាព និងប្រសិទ្ធភាពនៃការបើកដំណើរការឡើងវិញនូវគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្រោមឱវាទ ក្រសួងសូមធ្វើការណែនាំដល់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ចូលរួមសហការ និងអនុវត្តដូចខាងក្រោម៖

- ត្រូវពង្រឹងវិធានការការពារ ទប់ស្កាត់ និងឆ្លើយតបការរីករាលដាលជំងឺកូវីដ-១៩ របស់ក្រសួងសុខាភិបាល ដូចជា៖
  - រៀបចំធ្វើអនាម័យបោសសម្អាតតាមបន្ទប់រៀន សាលសហសិក្សា សាលប្រជុំ បណ្ណាល័យ អន្តេវាសិកដ្ឋាន រោងជាង បន្ទប់ពិសោធន៍ អាហារដ្ឋាន បង្គន់អនាម័យ សួនកំសាន្ត ទីលានកីឡា សម្ភារប្រើប្រាស់ និងកាកសំណល់ផ្សេងៗទុកដាក់ឱ្យបានត្រឹមត្រូវ
  - រៀបចំកៅអីអង្គុយឱ្យមានគម្លាតពីគ្នាយ៉ាងតិច ១,៥ម៉ែត្រ ព្រមទាំងកំណត់ចំនួនសិក្ខាកាម សិស្ស និស្សិត ទៅតាមទំហំនៃបន្ទប់រៀន
  - រៀបចំគ្រែក្នុងបន្ទប់ស្នាក់នៅនៃអន្តេវាសិកដ្ឋាន ដោយរក្សាគម្លាតតាមវិធានការរបស់ក្រសួងសុខាភិបាល
  - បាញ់ថ្នាំសម្លាប់មេរោគក្នុងបរិវេណគ្រឹះស្ថាន តាមបន្ទប់រៀន សាលសហសិក្សា សាលប្រជុំ បណ្ណាល័យ អន្តេវាសិកដ្ឋាន រោងជាង បន្ទប់ពិសោធន៍ អាហារដ្ឋាន បង្គន់អនាម័យ សួនកំសាន្ត និងទីលានកីឡា
  - ណែនាំដល់បុគ្គលិក មន្ត្រីរាជការ គ្រូ សិក្ខាកាម សិស្ស និស្សិត ឱ្យពាក់ម៉ាស់ និងកុំឱ្យមានការប្រមូលផ្តុំ ត្រូវមានគម្លាតពីគ្នាយ៉ាងតិច ១,៥ម៉ែត្រ

  ○ បើកបង្អួចឱ្យមានខ្យល់ និងពន្លឺចេញចូលបានល្អ នៅតាមបន្ទប់រៀន សាលសហសិក្សា សាលប្រជុំ បណ្ណាល័យ អន្តេវាសិកដ្ឋាន រោងជាង បន្ទប់ពិសោធន៍ និងអាហារដ្ឋាន
  ○ រៀបចំឱ្យមានកន្លែងលាងដៃជិតបន្ទប់រៀន សាលសហសិក្សា សាលប្រជុំ បណ្ណាល័យ អន្តេវាសិកដ្ឋាន រោងជាង បន្ទប់ពិសោធន៍ អាហារដ្ឋាន និងបង្គន់អនាម័យ
  ○ ចាត់តាំងឱ្យមានក្រុមការងារទទួលបន្ទុកការវាស់កំដៅ និងលាងសម្អាតដៃ នៅគ្រប់ច្រកចេញ-ចូល នៃបរិវេណគ្រឹះស្ថាន។ ករណីរកឃើញមានកម្តៅចាប់ពី៣៧,៥ អង្សាសេឡើងទៅ មិនត្រូវអនុញ្ញាតឱ្យចូលក្នុងបរិវេណគ្រឹះស្ថានឡើយ ហើយត្រូវណែនាំឱ្យទៅសម្រាកនៅផ្ទះ ឬទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យ ឬមណ្ឌលសុខភាព

- លើកទឹកចិត្តឱ្យបុគ្គលិក មន្ត្រីរាជការ គ្រូ សិក្ខាកាម សិស្ស និស្សិត និងអ្នកពាក់ព័ន្ធ ឱ្យយកទឹកស្អាតមកពីផ្ទះសម្រាប់ទុកទទួលទានផ្ទាល់ខ្លួន
- ត្រូវសហការជាមួយមាតា បិតា អាណាព្យាបាល សិក្ខាកាម សិស្ស និស្សិត និងអ្នកពាក់ព័ន្ធ ផ្តល់ព័ត៌មានអំពីសុខភាព និងប្រវត្តិនៃការធ្វើដំណើរក្រៅប្រទេសរបស់សិក្ខាកាម សិស្ស និស្សិត
- ត្រូវសហការជាមួយមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក ដើម្បីចុះត្រួតពិនិត្យ និងជំរុញការអនុវត្តវិធានការអនាម័យ ការទប់ស្កាត់ និងឆ្លើយតបការរីករាលដាលជំងឺកូវីដ-១៩ របស់ក្រសួងសុខាភិបាល
- ត្រូវសម្របសម្រួល និងអន្តរាគមន៍ ទៅគ្រប់អង្គភាពពាក់ព័ន្ធ ក្នុងករណីមានការសង្ស័យមានអ្នកឆ្លងជំងឺកូវីដ-១៩ នៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ត្រូវរៀបចំពាក្យស្នើសុំបើកគ្រឹះស្ថានឡើងវិញបញ្ជូនមកមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (សម្រាប់គ្រឹះស្ថានដែលបានចុះបញ្ជិកានៅមន្ទីរ) និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈនាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា (សម្រាប់គ្រឹះស្ថានដែលបានចុះបញ្ជិកានៅក្រសួង)
- ត្រូវធ្វើរបាយការណ៍ប្រចាំខែស្តីពីសកម្មភាពដំណើរការគ្រឹះស្ថាន និងវិធានការការពារទប់ស្កាត់ និងឆ្លើយតបការរីករាលដាលជំងឺកូវីដ-១៩ ផ្ញើមកក្រសួង (នាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា) ឱ្យបានទៀងទាត់រៀងរាល់ថ្ងៃសុក្រនៃសប្តាហ៍ទី៣នៃខែនីមួយៗ។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្រោមឱវាទក្រសួងទាំងអស់ ត្រូវចូលរួមសហការអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ចន្ទ ១២ រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០២០
រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**ចម្លងជូន៖**
- គ្រប់រដ្ឋបាលរាជធានី-ខេត្ត
- អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- គ្រប់អង្គភាពពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរ ក.ប. រាជធានី-ខេត្ត
- គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្រោមឱវាទ
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ